ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៩៩ កយ.ប្រក.២៥

# ប្រកាស

## ស្ដីពី

## ការបង្កើតគណៈកម្មការត្រួតពិនិត្យ និងគណៈកម្មការអនុវត្ត ការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកនៅតាមសាលាដំបូងរាជធានី ខេត្ត

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៥/០០២ ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២៥ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌



មហាវិថីសម្ដេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

## សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីការបង្កើតយន្តការដើម្បីអនុវត្ត និងត្រួតពិនិត្យការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក ស្របតាមច្បាប់ស្ដីពីការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក ដែលរួមមាន៖

- គណៈកម្មការត្រួតពិនិត្យការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក ដែលសរសេរជាអក្សរកាត់ថា "**គ.ត.ច.**" និង
- គណៈកម្មការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក នៅតាមសាលាដំបូងរាជធានី ខេត្ត ដែលសរសេរជាអក្សរកាត់ថា "**គ.ច.ស.ជ.**"។

**ប្រការ២.-**

គ.ត.ច. មានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ខាន់ ចណ្ណរ៉ា** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ប្រធាន |
| ២-ឯកឧត្តម | **ទឹម ស៊ីផា** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធានទី១ |
| ៣-ឯកឧត្តម | **ផូច សំភី** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ | អនុប្រធានប្រចាំការ |
| ៤-លោកជំទាវ | **សុន សុខាលីដា** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកនៃ អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ | អនុប្រធាន |
| ៥-ឯកឧត្តម | **ខាត់ ឆច័ន្ទ** | ទីប្រឹក្សា និងជានាយករងខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ៦-ឯកឧត្តម | **សៀង គង់** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ | សមាជិក |
| ៧-លោក | **យស អូន** | ប្រធាននាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ នៃសាលាជម្រះក្តី | សមាជិក |
| ៨-លោកស្រី | **យ៉ុន ច័ន្ទសោភា** | ប្រធាននាយកដ្ឋានគ្រប់គ្រងវត្ថុតាង និងផលនៃបទល្មើស | សមាជិក |
| ៩-លោក | **ហ៊ឹម ឧិចតេលា** | ប្រធាននាយកដ្ឋានអាជ្ញាសាលា | សមាជិក |
| ១០-លោក | **ឆុន ករុណា** | សមាជិកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | សមាជិក |
| ១១-លោក | **ហោង ភី** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១២-លោក | **លឹម ឧិតារ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៣-លោក | **ឈួន គីមឡៀង** | មន្ត្រីគ្រប់គ្រងរដ្ឋបាល | លេខាធិការ |
| ១៤-លោក | **អេង ចាន់សុភត្រ្តា** | មន្ត្រីគ្រប់គ្រងរដ្ឋបាល | លេខាធិការ |
| ១៥-លោក | **ឈាង គិចស៊ុន** | មន្ត្រីគ្រប់គ្រងរដ្ឋបាល | លេខាធិការ។ |

គ.ត.ច. មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យ និងលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីសម្រេចអំពីការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក តាមសំណើរបស់ **គ.ច.ស.ជ.**
- តាមដាន និងត្រួតពិនិត្យលើការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យករបស់ **គ.ច.ស.ជ.** ដើម្បីធានាប្រសិទ្ធភាព និងតម្លាភាពក្នុងការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក

- តាមដាន ស្រាវជ្រាវ ប្រមូល កត់ត្រា និងគ្រប់គ្រងទិន្នន័យនូវវត្ថុចាប់យកនៅតាមស្ថាប័នតុលាការ និងស្ថាប័នអយ្យការ
- ចុះពិនិត្យ និងវាយតម្លៃអំពីស្ថានភាព និងការគ្រប់គ្រងវត្ថុចាប់យកនៅតាមសាលាដំបូងរាជធានី ខេត្ត
- ផ្តល់យោបល់ និងលើកសំណើជាដំណោះស្រាយជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លើបញ្ហាប្រឈម និងបញ្ហាបច្ចេកទេសនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក
- សិក្សា ស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំនានាដើម្បីអនុវត្តច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក ឱ្យមានប្រសិទ្ធភាព
- រៀបចំផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់មន្ត្រីជំនាញដែលពាក់ព័ន្ធនៅតាមសាលាដំបូងរាជធានី ខេត្ត
- រៀបចំផែនការសកម្មភាព និងផែនការថវិកាសម្រាប់គាំទ្រដល់ដំណើរការការងារ
- ធ្វើរបាយការណ៍បូកសរុបអំពីវឌ្ឍនភាពនៃការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកនៅតាមសាលាដំបូងរាជធានី ខេត្ត ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**ប្រការ៣.-**

គ.ច.ស.ជ. មានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ប្រធានសាលាដំបូង ឬព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្ត ឬតំណាង | | ប្រធាន |
| ២-តំណាងអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ | ១រូប | អនុប្រធាន |
| ៣-តំណាងអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ | ១រូប | អនុប្រធាន |
| ៤-ប្រធានលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី ខេត្ត | | អនុប្រធានប្រចាំការ |
| ៥-ប្រធានអង្គភាពអាជ្ញាសាលា ចំពោះសាលាដំបូងដែលមានអង្គភាពអាជ្ញាសាលា ឬតំណាង | | អនុប្រធាន |
| ៦-មន្ត្រីលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី ខេត្ត ទទួលបន្ទុកការងារវត្ថុតាង/វត្ថុចាប់យក | ២រូប | សមាជិក |
| ៧-មន្ត្រីលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងរាជធានី ខេត្ត | ១រូប | លេខាធិការ។ |

សមាសភាពជាក់ស្តែងនៃ គ.ច.ស.ជ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ចំពោះការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកនៅដំណាក់កាលអយ្យការ គ.ច.ស.ជ. ត្រូវស្ថិតក្រោមការដឹកនាំរបស់ព្រះរាជអាជ្ញា ឬតំណាង។ ចំពោះការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកនៅដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ គ.ច.ស.ជ. ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធានសាលាដំបូង ឬតំណាង។

ក្នុងករណីចាំបាច់ ប្រធាន គ.ច.ស.ជ. អាចអញ្ជើញតំណាងអង្គភាពនគរបាលយុត្តិធម៌ដែលជាម្ចាស់ករណី ឬដែលមានការពាក់ព័ន្ធនឹងវត្ថុចាប់យក ឬស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមក្នុងការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក។

**ប្រការ៤.-**

គ.ច.ស.ជ. មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- លើកសំណើជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អំពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក នៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងសាមី តាមរយៈ គ.ត.ច.
- រៀបចំ និងអនុវត្តការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកនៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងសាមី ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកនៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងសាមី ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ តាមរយៈ **គ.ត.ច.**
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកនៅតាមសាលាដំបូង និងអយ្យការអមសាលាដំបូងសាមី។

**ប្រការ៥.-**

**គ.ត.ច.** ត្រូវដំណើរការកិច្ចប្រជុំរបស់ខ្លួន តាមការអញ្ជើញ និងក្រោមការដឹកនាំរបស់ប្រធាន **គ.ត.ច.**។ ប្រធាន **គ.ត.ច.** អាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំជំនួសបាន ក្នុងករណីប្រធានអវត្តមាន។

**គ.ត.ច.** អាចប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌ ក្នុងការបំពេញមុខងាររបស់ខ្លួន។

**ប្រការ៦.-**

**គ.ច.ស.ដ.** ត្រូវដំណើរការកិច្ចប្រជុំរបស់ខ្លួន តាមការអញ្ជើញ និងក្រោមការដឹកនាំរបស់ប្រធាន **គ.ច.ស.ដ.**។ ប្រធាន **គ.ច.ស.ដ.** អាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំជំនួសបាន ក្នុងករណីប្រធានអវត្តមាន។

**គ.ច.ស.ដ** អាចប្រើប្រាស់ត្រារបស់សាលាដំបូង ឬរបស់អយ្យការអមសាលាដំបូងសាមី ក្នុងការបំពេញមុខងាររបស់ខ្លួន។

**ប្រការ៧.-**

**គ.ត.ច.** ប្រើប្រាស់ថវិការបស់ក្រសួងយុត្តិធម៌ ក្នុងការអនុវត្តការងាររបស់ខ្លួន។

**គ.ច.ស.ដ.** ប្រើប្រាស់ថវិការបស់សាលាដំបូងសាមី ក្នុងការអនុវត្តការងាររបស់ខ្លួន។

**ប្រការ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ សាលាដំបូង និងអង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្ត និងប្រធានអង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ២ និងប្រការ៣ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្ស ១៤កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- តុលាការកំពូល និងមហាអយ្យការអមតុលាការកំពូល
- គ្រប់សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ